# ការវាយតម្លៃបឋមលើផលប៉ះពាល់
# សេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍
# ក្រសួងអប់រំ យុវជន និងកីឡា

លេខយោង:

កាលបរិច្ឆេទចាប់ផ្តើម:

កាលបរិច្ឆេទបញ្ចប់:

**អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម**

ប្រកាសនេះ កំណត់អំពីការបង្កើតនិងការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដើម្បីផ្តល់ឱកាសឱ្យប្រជាពលរដ្ឋគ្រប់រូបមានលទ្ធភាពរៀនសូត្រពេញមួយជីវិត។ នីតិបុគ្គលសាធារណៈ នីតិបុគ្គលឯកជន ឬរូបវន្តបុគ្គល មានសិទ្ធិស្នើសុំបង្កើតមជ្ឈមណ្ឌលសិក្សាសហគមន៍ ដោយគោរព និងបំពេញឱ្យបាននូវលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

១. ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

២. រចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់

៣. កម្មវិធីសិក្សាច្បាស់លាស់

៤. មុខសញ្ញាអ្នកសិក្សា

៥. ជំនាញមុខរបរ

៦. គ្រូជំនាញមុខរបរ

៧. សម្ភារបរិក្ខារ

៨. រចនាសម្ព័ន្ធទ្រទ្រង់ច្បាស់លាស់

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការបង្កើតមជ្ឈមណ្ឌលសិក្សាសហគមន៍នៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។

**ប្រភេទបញ្ញត្តិកម្ម**

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងៗទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☐ | ☑ | ☐ | ☐ | ☐ |

**ផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មលើវិស័យ៖**

☐សេដ្ឋកិច្ច ☑សង្គមកិច្ច ☐បរិស្ថាន ☐ផ្សេងៗ

## ១. ការកំណត់បញ្ហា

១.ក បញ្ហាចម្បងដែលបញ្ញត្តិកម្មមានបំណងដោះស្រាយ ដោយផ្តល់អំណះអំណាង (ភស្តុតាង/ភាពជាក់ស្តែង ប្រសិនបើចាំបាច់)

១. គ្មានជំនាញមុខរបរពិតប្រាកដ

ប្រជាពលរដ្ឋនៅតាមមូលដ្ឋានប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃតាមទម្លាប់តាំងពីដូនតាមក ដូចជា ការធ្វើស្រែចម្ការ ការចិញ្ចឹមសត្វ ការថែរក្សាទុកដាក់ទ្រព្យសម្បត្តិ ជីវភាពរស់នៅប្រចាំថ្ងៃជាដើម។ ការប្រែក្លាយពីការប្រកបរបរចិញ្ចឹមជីវិតតាមទម្លាប់ទៅជាការចិញ្ចឹមជីវិតមួយដែលមានផែនការជីវិតជាក់លាក់ និងបង្កើនសមត្ថភាពក្នុងការទស្សន៍ទាយ ឬព្យាករណ៍អំពីអនាគតរបស់ខ្លួន គឺទាមទារឱ្យប្រជាពលរដ្ឋមានជំនាញមុខរបរពិតប្រាកដ។

២. គ្រោះមិនចេះអក្សរ

ប្រជាពលរដ្ឋដែលមិនចេះអក្សរនៅក្នុងសង្គមកម្ពុជាមាន១៦%ភាគរយ។ ការមិនចេះអក្សរនេះ បានធ្វើឱ្យប្រជាពលរដ្ឋបាត់បង់នូវព័ត៌មានជាក់លាក់ និងធ្វើឱ្យប្រជាពលរដ្ឋងាយនឹងទទួលរងនូវការបោកប្រាស់ពីជនមួយចំនួនដែលគ្មានគុណធម៌នៅក្នុងជីវិត។ ដូច្នេះការកាត់បន្ថយនិងទប់ស្កាត់គ្រោះមិនចេះអក្សរនេះ គឺជាភាពចាំបាច់ដែលមិនអាចខ្វះបាន។

៣. បំណិនជីវិតនៅមានកម្រិត

បំណិនជីវិតរបស់ប្រជាពលរដ្ឋមូលដ្ឋាននៅមានកម្រិត ដែលទាមទារឱ្យមានការចូលរួមដោះស្រាយពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីធ្វើឱ្យប្រសើរឡើងនូវបំណិនជីវិតរបស់ពលរដ្ឋ។

៤. ចំណាកស្រុក

ប្រជាពលរដ្ឋមួយចំនួនពុំមានបំណិនជីវិតជាក់លាក់ ស្របពេលជាមួយគ្នានឹងការប្រែប្រួលញឹកញាប់នៃអាកាសធាតុធ្វើឱ្យមានភាពលំបាកនិងមិនប្រក្រតីក្នុងការប្រកបរបរកសិកម្ម។ ប្រជាពលរដ្ឋមួយចំនួនសម្រេចចិត្តធ្វើចំណាកស្រុក ដែលពេលខ្លះចំណាកស្រុកនោះត្រូវបានធ្វើឡើងដោយប្រថុយប្រថាន។ ដើម្បីកាត់បន្ថយចំណាកស្រុក និងបង្កើនប្រសិទ្ធភាពក្នុងការប្រកបរបរកសិកម្ម សំដៅរួមចំណែកឆ្លើយតបទៅនឹងគោលនយោបាយនាំអង្ករចេញរបស់រាជរដ្ឋាភិបាល ការបង្កើតមជ្ឈមណ្ឌលសិក្សាសហគមន៍ សម្រាប់ជាទីកន្លែងផ្តល់ចំណេះដឹង និងផ្លាស់ប្តូរបទពិសោធន៍គឺជាការចាំបាច់។

១.ខ បញ្ហាពាក់ព័ន្ធផ្សេងទៀតដែលបញ្ញត្តិកម្មអាចជួយដោះស្រាយផងដែរ ដោយផ្តល់អំណះអំណាង(ភស្តុតាង/ភាពជាក់ស្តែង ប្រសិនបើចាំបាច់)

សេចក្តីព្រាងប្រកាសនេះ ត្រូវបានរៀបចំឡើង ឆ្លើយតបទៅនឹងអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធ។

១.គ សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តមានស្រាប់ ដែលពាក់ព័ន្ធឬប្រហាក់ប្រហែល។ ចូរបញ្ជាក់ថា តើហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តទាំងនេះ មិនទាន់គ្រប់គ្រាន់?

- អនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការគ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធ
- អនុក្រឹត្យលេខ ៥៨ អនក្រ. ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

អនុក្រឹត្យលេខ ២០ អនក្រ.បក ត្រង់មាត្រា១៣ បានចង្អុលឱ្យមានការរៀបចំប្រកាសនេះឡើង។

១. ឃ តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ? (ប្រសិនបើមាន សូមពន្យល់)

សំណើបញ្ញត្តិកម្មនេះ មិនមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងឡើយ។

## ២. គោលបំណង តើយើងចង់សម្រេចបានអ្វី?

ការរៀបចំសេចក្តីព្រាងប្រកាសនេះឡើង ក្នុងគោលបំណងឱ្យមជ្ឈមណ្ឌលសិក្សាសហគមន៍ទាំងអស់ដែលបង្កើតឡើងមាននិរន្តភាព ហើយត្រូវតែគោរពនិងអនុវត្តតាមគោលការណ៍ដែលក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ដូចជា ទីតាំង និយាមអគារ និយាមបន្ទប់រៀន និយាមគ្រូ និយាមអ្នកសិក្សា អនាម័យ និងបរិស្ថានជាដើម ដើម្បីផ្តល់សេវាអប់រំពេញមួយជីវិតជូនដល់ប្រជាពលរដ្ឋ។

## ៣. ជម្រើស

ជម្រើសផ្សេងៗរួមទាំងសំណើបញ្ញត្តិកម្ម (សម្រាប់ការវិភាគលើផលប៉ះពាល់)

១. ពង្រឹងការអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់
២. សំណើប្រកាសថ្មី

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពាក់ព័ន្ធ និងផលចំណេញ

៤.១ ការកំណត់ភារកិច្ច និងប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១៖ ពង្រឹងការអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់ | - បន្ទុកចំណាយលើការចុះត្រួតពិនិត្យដើម្បីពង្រឹងមជ្ឈមណ្ឌលសិក្សាសហគមន៍<br>- បន្ទុកចំណាយលើការបង្កើតឧបករណ៍សម្រាប់ប្រៀប | គ្មាន |

| | | |
|---|---|---|
| | រៀបស្ថានភាពជាក់ស្តែងរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍និងការកំណត់របស់លិខិតបទដ្ឋានដែលមានស្រាប់ | |
| ជម្រើសទី២៖ សេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ | - បន្ទុកចំណាយលើការរៀបចំសេចក្តីព្រាងប្រកាសថ្មី<br>- បន្ទុកចំណាយលើការបណ្តុះបណ្តាល<br>- បន្ទុកចំណាយលើការបោះពុម្ព ការផ្សព្វផ្សាយ<br>- បន្ទុកចំណាយលើការចុះពិនិត្យទីតាំងមជ្ឈមណ្ឌលសិក្សាសហគមន៍<br>- បន្ទុកចំណាយលើការសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍ | - គ្មាន |

៤.២ ការកំណត់ប្រភេទនៃផលចំណេញ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១៖ ពង្រឹងការអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់ | - រក្សាស្ថានភាពដើមនិងសុពលភាពនៃលិខិតបទដ្ឋានដែលមានស្រាប់ | - គ្មាន |
| ជម្រើសទី២៖ សេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ | - បានបង្ហាញនូវការយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋ ប្រជាពលរដ្ឋនឹងទទួលបាននូវមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលមានលក្ខណស្តង់ដា ទទួលបាននូវផាសុខភាព<br>- បានផ្តល់នូវសេវាអប់រំពេញមួយជីវិតជូនប្រជាពលរដ្ឋ ប្រជាពលរដ្ឋនឹងទទួលបាន | - គ្មាន |

| | | |
|---|---|---|
| | នូវសេវាអប់រំពេញមួយជីវិត | |

៤.៣ វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១៖ ពង្រឹងការអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់ | | | |
| ជម្រើសទី២៖ សេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ | | | |

## ៥. កិច្ចពិគ្រោះយោបល់

ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យើងឃើញថារាជរដ្ឋាភិបាលមានលទ្ធភាពថវិកាគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់លើការរៀបចំស្តង់ដាមជ្ឈមណ្ឌលសិក្សាសហគមន៍។ ម្យ៉ាងវិញទៀត តាមផែនការដែលបានព្រមព្រៀងគ្នា គឺចាប់ពីឆ្នាំ២០១៤-២០១៨ មជ្ឈមណ្ឌលសិក្សាសហគមន៍នឹងត្រូវបានសាងសង់ចំនួនតែ២៤ប៉ុណ្ណោះ។ លើសពីនេះទៀត ការបង្កើតមជ្ឈមណ្ឌលសិក្សាសហគមន៍នេះ ត្រូវបានដាក់បញ្ចូលក្នុងផែនការថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា និងមានការសម្រេចដោយរដ្ឋសភាទៅតាមឆ្នាំថវិកានីមួយៗ។

## ៦. សន្និដ្ឋាន

តើចាំបាច់ធ្វើ RIS ដែរឬទេ?

☐ចាំបាច់

☑មិនចាំបាច់

បញ្ញត្តិកម្មដែលស្នើឡើងនេះ មិនមានផលប៉ះពាល់ដល់ធុរកិច្ចឡើយ ប៉ុន្តែបញ្ញត្តិកម្មនេះនឹងផ្តល់នូវផលវិជ្ជមានសម្រាប់ប្រជាពលរដ្ឋជាពិសេសពលរដ្ឋនៅតាមសហគមន៍។ ដូច្នេះជម្រើសទី២ គួរត្រូវបានជ្រើសរើស។

## ៧. ការអនុវត្តនិងការតាមដានត្រួតពិនិត្យ

៧.១ តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

| |
|---|
| បើសិនជាសំណើរៀបចំប្រកាសថ្មីនេះត្រូវបានជ្រើសរើស វិធានការដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលប្រតិបត្តិគឺ ត្រូវកំណត់ពេលវេលាជាក់លាក់ក្នុងការចុះពិនិត្យតាមដាននិងវាយតម្លៃលើដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍។ |

៧.២ តើគួរធ្វើការពិនិត្យ/តាមដានបញ្ញត្តិកម្មនេះឡើងវិញក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានប្រតិបត្តិដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះ គួរត្រូវបានពិនិត្យឡើងវិញ/តាមដានយ៉ាងដូចម្តេចនិងនៅពេលណា?

| |
|---|
| ក្នុងករណីសំណើប្រកាសថ្មីត្រូវបានជ្រើសរើស ប្រកាសថ្មីនេះគួរត្រូវបានពិនិត្យឡើងវិញរៀងរាល់៥ឆ្នាំម្តង។ |

| ដំណើរការ | ឈ្មោះ | មុខងារ | ហត្ថលេខា | កាលបរិច្ឆេទ | ទំនាក់ទំនង |
|---|---|---|---|---|---|
| រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា | ឯកឧត្តម ស៊ន សេងហុក | ប្រធាន | | | |
| | លោក ប៉ូវ វី | អនុប្រធាន | | | |
| | លោកស្រី ហេង ងួនឡាង | សមាជិក | | | |
| | លោក សឹង ប្រាក់ | សមាជិក | | | |
| ត្រួតពិនិត្យដោយ | លោកជំទាវ ស៊ាង សុផល្លា | | | | |
| ឯកភាពដោយ | ឯកឧត្តម ប៊ិច សុខា | | | | |